# សន្តិសុខស្បៀង និងអាហារូបត្ថម្ភនៅកម្ពុជា៖ លំនាំ និងមាគ៌ាឆ្ពោះទៅរកជោគជ័យ

## ឯកសារពិភាក្សាគោលនយោបាយ[1]

### សេចក្ដីផ្ដើម

នៅប៉ុន្មានឆ្នាំថ្មីៗនេះ អាស៊ីខាងត្បូង និងអាស៊ីអាគ្នេយ៍ មានកំណើនសេដ្ឋកិច្ចលឿនគួរឱ្យកត់សម្គាល់ ដែលជំរុញឡើងដោយកំណើនយ៉ាងលឿនរបស់ប្រទេសចិន និងឥណ្ឌា ។ ដោយសារមានការផ្លាស់ប្ដូរនៅក្នុងតំបន់បែបនេះ កម្ពុជាក៏ទទួលបានផលចំណេញពីទំនាក់ទំនងជិតស្និទ្ធជាមួយប្រទេសជិតខាងផ្ទាល់ ដូចជា ថៃ និងវៀតណាម និងប្រទេសដទៃទៀតនៅក្នុងតំបន់ ដូចជា ចិន ជាដើម ។ ប្រទេសវៀតណាម ថៃ និងចិន ជាដៃគូពាណិជ្ជកម្មដ៏សំខាន់របស់កម្ពុជា ហើយក៏បានផ្ដល់ឱកាសការងារជាច្រើនដល់ប្រជាជនកម្ពុជាដែរ តាមរយៈការធ្វើចំណាកស្រុកឆ្លងកាត់ព្រំដែន ។ ម្យ៉ាងទៀត កម្ពុជាកំពុងតាមដានយ៉ាងជិតដល់លើការរីកចម្រើន និងកត្តារាំងស្ទះការអភិវឌ្ឍនៅវៀតណាម ដែលជាប្រទេសមានសេដ្ឋកិច្ចកំពុងស្ទុះឡើង និង នៅថៃ ដែលជាប្រទេសមានប្រាក់ចំណូលឡើងដល់កម្រិតមធ្យម និងសម្រេចបាន កំណើនសេដ្ឋកិច្ចលឿនប្រកបដោយចីរភាពក្នុងរយៈពេលបួនទសវត្សរ៍មុនពេលមានវិបត្តិអាស៊ី ។

ក្នុងស្ថានភាពរួមនៃអន្តរកម្ម និងសមាហរណកម្មសេដ្ឋកិច្ចក្នុងតំបន់ ការអភិវឌ្ឍនៅកម្ពុជា និងឥទ្ធិពលនៃការអភិវឌ្ឍ ទៅលើអាហារូបត្ថម្ភ និងសន្តិសុខស្បៀង អាចកាន់តែងាយយល់បានតាមការប្រៀបធៀបជាមួយបណ្ដាប្រទេសនៅអាស៊ីខាងត្បូង និងអាស៊ីអាគ្នេយ៍ ។ ម្យ៉ាងទៀត បទពិសោធន៍ដែលប្រទេសអាស៊ីដទៃទៀតទទួលបាននៅដំណាក់កាលដំបូងនៃការអភិវឌ្ឍ និងមាគ៌ាដែលគេប្រកាន់យក ដើម្បីទទួលបានជោគជ័យដូចសព្វថ្ងៃ អាចផ្ដល់ជាព័ត៌មានដ៏មានប្រយោជន៍ ដើម្បីវាយតម្លៃពីដំណាក់កាលបច្ចុប្បន្ននៃការអភិវឌ្ឍនៅកម្ពុជា និងព្យាករណ៍ពីឱកាស និងបញ្ហាប្រឈមដែលកម្ពុជាត្រូវជួបប្រទះនៅពេលអនាគត ។

អត្ថបទនេះ បង្ហាញជារួមពី ស្ថានភាពសន្តិសុខស្បៀង និងអាហារូបត្ថម្ភនៅកម្ពុជា ដោយឈរលើទស្សនវិស័យនៃការអភិវឌ្ឍក្នុងតំបន់ ។ អត្ថបទនេះ មានគោលបំណងស្វែងយល់ពីស្ថានភាពបច្ចុប្បន្ននៅក្នុងបរិបទនៃការផ្លាស់ប្ដូរសេដ្ឋកិច្ច និងកំណត់នូវលំនាំរួមគ្នា និងលំនាំខុសៗគ្នា រវាងកម្ពុជា និងប្រទេសដទៃទៀតក្នុងតំបន់ ។ មេរៀនដែលទទួលបានពីប្រទេសទាំងនេះ អាចជួយដល់ការរៀបចំយុទ្ធសាស្ត្រអភិវឌ្ឍន៍ប្រកបដោយប្រសិទ្ធភាព និងអន្តរាគមន៍ជាក់លាក់លើអាហារូបត្ថម្ភ និងសន្តិសុខស្បៀងនៅកម្ពុជា ។

អត្ថបទនេះ ចែកចេញជាបីផ្នែក ។ ផ្នែកទីមួយ បង្ហាញពីក្របខណ្ឌទស្សនទានមួយសម្រាប់វិភាគពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ដោយផ្សារភ្ជាប់នឹងយុទ្ធសាស្ត្រអភិវឌ្ឍន៍ ។ ក្របខណ្ឌនេះ សង្កត់ធ្ងន់ទៅលើអន្តរកម្ម និងចំណងទាក់ទងរវាងកត្តាផ្សេងៗដែលជះឥទ្ធិពលទៅលើស្ថានភាពអាហារូបត្ថម្ភ និងសន្តិសុខស្បៀងទាំងនៅកម្រិតម៉ាក្រូ និងមីក្រូ ។ ផ្នែកទីពីរ វិភាគពីស្ថានភាពបច្ចុប្បន្ននៃសន្តិសុខស្បៀង និងអាហារូបត្ថម្ភនៅកម្ពុជា ធៀបនឹងប្រទេសអាស៊ីខាងត្បូង និងអាស៊ីអាគ្នេយ៍ដទៃទៀត និងនិន្នាការនៃការអភិវឌ្ឍ ។ ទិន្នន័យមានស្រាប់ និងសូចនាករសំខាន់ៗនៃការអភិវឌ្ឍ និងអាហារូបត្ថម្ភ ត្រូវបានយកមកប្រើប្រាស់ ដើម្បីគូសបញ្ជាក់ពីតួនាទីនៃកំណើនសេដ្ឋកិច្ច ក្នុងការជំរុញសន្តិសុខស្បៀង និងអាហារូបត្ថម្ភឲ្យកាន់តែប្រសើរឡើង ។ ផ្នែកទីបី គឺជាសេចក្ដីសន្និដ្ឋាន ។

### ក្របខ័ណ្ឌទស្សនទាន និងកត្តាជំរុញសន្តិសុខស្បៀង

ទស្សនៈបច្ចុប្បន្ន ស្ដីពីសន្តិសុខស្បៀង បានផ្ដល់ជាក្របខ័ណ្ឌដ៏មានប្រយោជន៍ និងគ្រប់ជ្រុងជ្រោយមួយ សម្រាប់វិភាគពីស្ថានភាពអាហារូបត្ថម្ភ និងស្បៀងអាហារ និងស្វែងយល់ពីកត្តាជំរុញសំខាន់ៗ ។ និយមន័យរួមគ្នាសព្វថ្ងៃ ស្ដីពីសន្តិសុខស្បៀង ត្រូវបានកំណត់ឡើងក្នុងកិច្ចប្រជុំកំពូល ស្ដីពីស្បៀងអាហារសាកលកាលពីឆ្នាំ១៩៩៩ ។ សន្តិសុខស្បៀងកើតមានឡើង "នៅពេលមនុស្សទាំងអស់ មានលទ្ធភាពពេញលេញទាំងផ្នែករូបវ័ន្ត ផ្នែកសង្គម និងផ្នែកសេដ្ឋកិច្ច ក្នុងការទទួលបានស្បៀងអាហារមានសុវត្ថិភាព និងមានជីវជាតិគ្រប់គ្រាន់ សម្រាប់បំពេញតម្រូវការរបបអាហារ និងចំណង់ចំណូលចិត្តនៅគ្រប់ពេល ដើម្បីឲ្យមានជីវិតរស់នៅយ៉ាងសកម្ម និងសុខភាពមាំមួន" (FAO 1996) ។ ការសម្រេចបានស្ថានភាពបែបនេះ ទាមទារឱ្យមានសកម្មភាពរួមគ្នានៅកម្រិត បុគ្គល គ្រួសារ ជាតិ តំបន់ និងសាកល (FAO 1996) ។ ក្នុងកិច្ចប្រជុំកំពូល ស្ដីពីសន្តិសុខស្បៀងសាកលកាលពីឆ្នាំ២០០៩ សហគមន៍អន្តរជាតិបានបញ្ជាក់គាំទ្រដល់និយមន័យនេះ និងសង្កត់ធ្ងន់ថា "សមាសធាតុអាហារូបត្ថម្ភត្រូវមានជាចាំបាច់ក្នុងនិយមន័យនេះ" (FAO 2009) ។ និយមន័យដែលមានសមាសធាតុច្រើនបូកបញ្ចូលគ្នានៃសន្តិសុខស្បៀង ត្រូវបានយកមកប្រើជាទូទៅក្នុងអត្ថបទនេះ ។

ក្រាហ្វិក ១ បង្ហាញពីក្របខណ្ឌទស្សនទាន សម្រាប់ការវិភាគពីសន្តិសុខស្បៀង ដែលជាអាទិភាពមួយក្នុងយុទ្ធសាស្ត្រ

---

១ អត្ថបទនេះរៀបចំឡើងដោយបណ្ឌិត Olivier Ecker និង បណ្ឌិត Xinshen Diao នៃវិទ្យាស្ថានស្រាវជ្រាវគោលនយោបាយស្បៀងអន្តរជាតិ (IFPRI) ។ អត្ថបទនេះផ្អែកលើឯកសារពិភាក្សាគោលនយោបាយ រៀបចំសម្រាប់កិច្ចប្រជុំបូកសរុប ស្ដីពី គោលនយោបាយកសិកម្ម និងសន្តិសុខស្បៀងនៅកម្ពុជា ដែលធ្វើឡើងកាលពី ថ្ងៃទី ៤ វិច្ឆិកា ២០១០ ។

អភិវឌ្ឍន៍របស់កម្ពុជា ។ ការស្វែងរកឧបករណ៍គោលនយោបាយ និងយុទ្ធសាស្ត្រដ៏សក្តិសិទ្ធ ដើម្បីសម្រេចបានសន្តិសុខស្បៀង តាមនិយមន័យកំណត់ឡើងដោយកិច្ចប្រជុំកំពូល តម្រូវឱ្យមាន វិធីសាស្ត្រគ្រប់ជ្រុងជ្រោយ និងបូកបញ្ចូលគ្នា និងទូលំទូលាយមួយ ដែលគិតគូរដល់លក្ខណៈច្រើនកម្រិត និងឆ្លងវិស័យ នៃបញ្ហាសន្តិសុខស្បៀង ។ ដោយសារមានផលប៉ះពាល់ធ្ងន់ធ្ងរ ពីវិបត្តិសេដ្ឋកិច្ចសាកលនាពេលថ្មីៗ ក្របខណ្ឌរបស់យើងបាន ពង្រីកក្របខណ្ឌមានស្រាប់ (ដែលផ្តោតទៅលើបញ្ហាអាហារូបត្ថម្ភ និងការប្រើប្រាស់ស្បៀងនៅកម្រិតបុគ្គល និងគ្រួសារ) ដោយដាក់បញ្ចូលនូវសមាសធាតុម៉ាក្រូសេដ្ឋកិច្ចថែមទៀត ។ ក្របខណ្ឌនេះ បានបង្ហាញពីច្រកផ្សេងៗនៅក្នុងប្រព័ន្ធសន្តិសុខស្បៀង ដែលក្នុងនោះ ម្ខាងមានអន្តរាគមន៍ផ្សេងៗនិងគោលនយោបាយ និងម្ខាងទៀតមានការប៉ះទង្គិចពីផ្នែកក្រៅ (ដូចជា វិបត្តិសាកល និងមហន្តរាយជាប់ទាក់ទងនឹងអាកាសធាតុ) ចូលមកលាយឡំគ្នា ជះឥទ្ធិពលទៅលើស្ថានភាពអាហារូបត្ថម្ភរបស់ប្រជាជន ក៏ដូចជា កត្តាសំខាន់ៗដែលកំណត់ពីស្ថានភាពអាហារូបត្ថម្ភ ។ វាក៏បង្ហាញដែរថា ការផ្លាស់ប្តូរក្នុងស្ថានភាពអាហារូបត្ថម្ភរបស់ប្រជាជន មិនត្រឹមតែជះឥទ្ធិពលទៅលើសុខុមាលភាពរបស់បុគ្គល និងគ្រួសារប៉ុណ្ណោះទេ គឺថែមទាំងទៅលើ ការអភិវឌ្ឍសេដ្ឋកិច្ច និងទម្រង់សង្គម ទាំងនៅកម្រិតសហគមន៍ និងកម្រិតជាតិ ។

ក្របខ័ណ្ឌទស្សនទាន បានបង្ហាញភាពខុសគ្នា រវាងសន្តិសុខស្បៀងនៅកម្រិតម៉ាក្រូ និងកម្រិតមីក្រូ ។ នៅកម្រិតម៉ាក្រូ គឺមាន ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ រីឯកម្រិតមីក្រូ គឺមានកម្រិតបុគ្គល និងកម្រិតគ្រួសារ ។ យើងមិនត្រូវយល់ច្រឡំថា សន្តិសុខស្បៀងកម្រិតម៉ាក្រូ ជាការផលិតស្បៀងបានគ្រប់គ្រាន់ សម្រាប់ផ្គត់ផ្គង់ខ្លួនឯងនោះទេ ពីព្រោះវាសំដៅទៅដល់គុណភាព នៃការផ្គត់ផ្គង់ និងតម្រូវការស្បៀងនៅក្នុងប្រទេស ឬក្នុងតំបន់ជាក់លាក់ណាមួយ ដែលនៅទីនោះតម្រូវការស្បៀង ទាំងបរិមាណ និងគុណភាព អាចដោះស្រាយបាន ដោយផលិតកម្មក្នុងស្រុក ឬដោយការនាំចូលជាក់ស្តែង ឬមធ្យោបាយទាំងពីរ (ករណីភាគច្រើន) ។ ក្នុងន័យនេះ សន្តិសុខស្បៀងកម្រិតម៉ាក្រូត្រូវបានកំណត់ឡើងដោយរចនាសម្ព័ន្ធ និងប្រតិបត្តិការនៃសេដ្ឋកិច្ចក្នុងស្រុក និងជាពិសេសវិស័យគន្លឹះជាក់លាក់មួយចំនួន ។ សន្តិសុខស្បៀងកម្រិតមីក្រូ ត្រូវបានកំណត់ដោយគ្រួសារ និងសមាជិកគ្រួសារគ្រប់រូប ដែលមានលទ្ធភាពទទួលបានស្បៀងអាហារមានបរិមាណ និងសារជាតិចិញ្ចឹមគ្រប់គ្រាន់ ក៏ដូចជា វត្តមានទ្រព្យសម្បត្តិគ្រួសារ និងលទ្ធភាពទទួលបានសេវា (សាធារណៈ) មូលដ្ឋាន ដែលជះឥទ្ធិពលទៅលើសុខភាព និងអាហារូបត្ថម្ភ របស់បុគ្គល ។ លទ្ធភាពទទួលបាន ភាគច្រើន ជួបកំហិតនៃមធ្យោបាយខាងសេដ្ឋកិច្ច ដូចជា ភាពក្រីក្រ (ដាច់ខាត) ជាដើម ។

## សន្តិសុខស្បៀង និងអាហារូបត្ថម្ភ ក្នុងការអភិវឌ្ឍ

ភស្តុតាងក្នុងប្រវត្តិសាស្ត្របង្ហាញថា ជាទូទៅកំណើនសេដ្ឋកិច្ចនាំឲ្យអាហារូបត្ថម្ភរបស់មនុស្សប្រែប្រួលប្រសើរឡើង ហើយផ្លូវដើរ ដែលមើលឃើញច្បាស់ និងកាត់ត្រង់បំផុតដើម្បីឈានពីកំណើន

ក្រាហ្វិក ១៖ ក្របខ័ណ្ឌទស្សនទាននៃសន្តិសុខស្បៀង សម្រាប់ការវិភាគយុទ្ធសាស្ត្រអភិវឌ្ឍន៍ប្រទេស




*ប្រភព៖ ចងក្រងដោយអ្នកនិពន្ធ*

សេដ្ឋកិច្ចទៅដល់អាហារូបត្ថម្ភល្អប្រសើរ គឺតាមរយៈប្រាក់ចំណូលគ្រួសារ ។ ប្រសិនបើកំណើននាំឱ្យចំណូលគ្រួសារកើនឡើង ពេលនោះប្រជាជនតែងអាចបង្កើនការហូប (ក្នុងករណីកត្តាផ្សេងៗស្ថិតនៅថេរ) នូវស្បៀងអាហារដែលមានសារជាតិចិញ្ចឹមកម្រិតខ្ពស់ ដូច្នេះហើយប្រជាជនភាគច្រើន ក៏មានស្ថានភាពអាហារូបត្ថម្ភកាន់តែប្រសើរ ។ ប៉ុន្តែឥទ្ធិពលជួយកែលំអបន្តិចម្តងៗនេះ អាចត្រូវរាំងស្ទះនៅតាមកម្រិតផ្សេងៗ និងត្រង់ចំណុចផ្សេងៗគ្នា ។ ច្រកមួយទៀតដើម្បីឱ្យកំណើនអាចជួយកែលំអស្ថានភាពអាហារូបត្ថម្ភ គឺអន្តរាគមន៍តាមគោលនយោបាយសាធារណៈ ។ កំណើនសេដ្ឋកិច្ចផ្តល់ប្រាក់ចំណូលឱ្យរដ្ឋបានកាន់តែច្រើន និងជួយឱ្យរដ្ឋាភិបាលអាចរៀបចំជាកម្មវិធីស្បៀង និងអាហារូបត្ថម្ភ ឬពង្រីកបន្ថែមនូវសេវាអប់រំ និងសុខភាពសាធារណៈ ។

ភាពខុសគ្នាជាខ្លាំងនៃស្ថានភាព និងការកែលំអអាហារូបត្ថម្ភពីមួយឆ្នាំទៅមួយឆ្នាំនៅតាមប្រទេសកំពុងអភិវឌ្ឍន៍ បានបង្ហាញថា កំណើនសេដ្ឋកិច្ចនៅប្រទេសមួយចំនួន បានជ្រាបចុះទៅដល់ប្រជាជនបានច្រើនជាងនៅប្រទេសដទៃទៀត ហើយរដ្ឋាភិបាលមួយចំនួនមានជោគជ័យច្រើន ក្នុងការប្រើប្រាស់កំណើនសេដ្ឋកិច្ចដើម្បីកែលំអស្ថានភាពអាហារូបត្ថម្ភ ប៉ុន្តែប្រទេសខ្លះទៀតមិនសូវបានជោគជ័យទេ និងប្រទេសខ្លះទៀតទទួលបរាជ័យតែម្តង ។ ប្រទេសទទួលជោគជ័យ ជាបណ្តាប្រទេសដែលបានបង្កើតជាកញ្ចប់គោលនយោបាយដ៏ស័ក្តិសិទ្ធិ ជំរុញឱ្យមានកំណើនប្រាក់ចំណូលកម្រិតខ្ពស់ មានចីរភាពល្អ និងផ្តល់ផលចំណេញដល់ជនក្រីក្រ ព្រមទាំងអន្តរាគមន៍ផ្សេងៗ ដែលផ្តោតចំក្រុមជនងាយរងគ្រោះបំផុត ។ ទោះបីជាការផ្សំបញ្ចូលគ្នានូវជម្រើសគោលនយោបាយ ត្រូវតែរៀបចំឱ្យសមស្របទៅនឹងលក្ខខណ្ឌជាក់លាក់ក្នុងប្រទេសនីមួយៗក៏ដោយ ក៏ប្រទេសដែលទទួលបានជោគជ័យនានា តែងមានលក្ខខណ្ឌពីដំបូងប្រហាក់ប្រហែលគ្នា ហើយច្រើនតែមានលំនាំរីកលូតលាស់ដូចគ្នា និងដើរតាមមាគ៌ាប្រហាក់ប្រហែលគ្នា ។

**ស្ថានភាពអភិវឌ្ឍន៍ និងសន្តិសុខស្បៀងនៅកម្ពុជា នៅក្នុងបរិបទតំបន់នេះ**

ជាបឋម គួរពិនិត្យពីស្ថានភាពបច្ចុប្បន្ននៃការអភិវឌ្ឍ និងសន្តិសុខស្បៀងនៅកម្ពុជា និងរកមើលថា នៅឆ្នាំណាដែលបណ្តាប្រទេសនៅអាស៊ីខាងត្បូង និងអាស៊ីអាគ្នេយ៍ដទៃទៀត សម្រេចបាននូវស្ថានភាពប្រហាក់ប្រហែលគ្នា ក្នុងនេះគួរជ្រើសយកប្រទេស ចិន ឡាវ ថៃ វៀតណាម ឥណ្ឌា និងបង់ក្លាដែស សម្រាប់ធ្វើការប្រៀបធៀប ។ សន្ទស្សន៍អភិវឌ្ឍន៍នៅកម្រិតម៉ាក្រូ ផលិតផលក្នុងស្រុកសរុប (ផសស) គិតក្នុងមនុស្សម្នាក់ ចំណែកឯសន្ទស្សន៍នៅកម្រិតមីក្រូ គឺជា សន្ទស្សន៍ដែលគេតែងប្រើប្រាស់ជាទូទៅក្នុងការកំណត់ ភាពក្រីក្រ ភាពស្រេកឃ្លាន កង្វះអាហារូបត្ថម្ភកុមារ និងអត្រាមរណភាពរបស់កុមារ ។ ទិន្នន័យ បានប្រមូលចងក្រងឡើងពីប្រភពសាធារណៈផ្សេងៗ ដូចជា សន្ទស្សន៍អភិវឌ្ឍន៍សាកល (WDI 2010) មូលដ្ឋានទិន្នន័យស្ថិតិសន្តិសុខស្បៀងរបស់អង្គការស្បៀងអាហារ និងកសិកម្ម (FSS 2010) និងមូលដ្ឋានទិន្នន័យសាកល ស្តីពីកង្វះអាហារូបត្ថម្ភ និងការលូតលាស់ធំធាត់នៃកុមារ របស់អង្គការសុខភាពពិភពលោក (GDCGM 2010) ។

កម្ពុជាមានកំណើនសេដ្ឋកិច្ចយ៉ាងលឿនចាប់ពីឆ្នាំ១៩៩៣មក ជាពិសេសចាប់តាំងពីឆ្លងចូលសហស្សវត្សរ៍ថ្មី (Naron 2009) ។ នៅចន្លោះឆ្នាំ១៩៩៣ និង ១៩៩៨ ផសស កើនឡើង ៦,៣% ក្នុងមួយឆ្នាំ និង ៩,៥% ជាមធ្យមក្នុងមួយឆ្នាំ នៅចន្លោះឆ្នាំ១៩៩៩ និង ២០០៨ ។ ទោះជាយ៉ាងនេះក្តី កម្ពុជានៅតែជាប្រទេសមានប្រាក់ចំណូលទាប ដោយមានប្រាក់ចំណូលជាមធ្យមក្នុងមនុស្សម្នាក់ ៥០០ដុល្លារ នៅឆ្នាំ២០០៨ (តារាង ១ ខ្ទង់ទី១) ។ ក្នុងចំណោមប្រទេសដែលយកមកប្រៀបធៀបក្នុងការសិក្សានេះ មានតែ ឡាវ និងបង់ក្លាដែស ប៉ុណ្ណោះ ដែលមានកម្រិតប្រាក់ចំណូលក្នុងមនុស្សម្នាក់ ទាបជាងកម្ពុជា ។ នៅឆ្នាំ២០០៨ ប្រាក់ចំណូលក្នុងមនុស្សម្នាក់នៅវៀតណាម និងឥណ្ឌា មានកម្រិតខ្ពស់ជាងកម្ពុជាបន្តិច ប៉ុន្តែចិនមានកម្រិតខ្ពស់ជាងមួយជាបួន និង ថៃមួយជាប្រាំ ។ ឥណ្ឌាឡើងដល់កម្រិតប្រាក់ចំណូលដូចកម្ពុជានាបច្ចុប្បន្ននៅឆ្នាំ២០០៣ ហើយវៀតណាម នៅឆ្នាំ២០០៤ រីឯចិនមានប្រាក់ចំណូលក្នុងមនុស្សម្នាក់ឡើងដល់កម្រិត ៥០០ដុល្លារ នៅឆ្នាំ២០០៣ និង ថៃ នៅឆ្នាំ១៩៧០ ។

វិសមភាពប្រាក់ចំណូលនៅកម្ពុជា មានលក្ខណៈកាន់តែធ្ងន់ធ្ងរ បើវាស់វែងដោយមេគុណ GINI នៅអំឡុងពេលដែលកម្ពុជាមានកំណើនលឿន ។ នៅឆ្នាំ១៩៩៤ មេគុណ GINI មានកម្រិត ០,៣៨ និងនៅឆ្នាំ២០០៧ មានកម្រិត ០,៤៤ ដែលជាតួលេខខ្ពស់បំផុតក្នុងចំណោមប្រទេសនៅអាស៊ីខាងត្បូង និងអាស៊ីអាគ្នេយ៍ ។ ទោះបីវិសមភាពប្រាក់ចំណូលកើនលឿនក្តី ក៏ភាពក្រីក្របានធ្លាក់ចុះយ៉ាងច្រើនគួរកត់សម្គាល់ ប៉ុន្តែវានៅតែប៉ះពាល់ដល់ប្រជាជនកម្ពុជាប្រមាណ ២៥% នាពេលបច្ចុប្បន្ន ។ ទោះបីកម្ពុជា មានការរីកចំរើនក្នុងពេលកន្លងមក ទាំងនៅតំបន់ជនបទ និងទីក្រុងក្តី ក៏អត្រាភាពក្រីក្រនៅជនបទ នៅតែមានកម្រិតខ្ពស់ជាងទីក្រុងដដែល ។ កំណើនសេដ្ឋកិច្ចលឿននៅទីក្រុង និងការកាត់បន្ថយភាពក្រីក្រយឺតៗនៅជនបទ អាចមានចំណែកក្នុងកំណើនវិសមភាពប្រាក់ចំណូលនៅទូទាំងប្រទេស ។ កម្ពុជាមានភាពក្រីក្រស្មើនឹង ប្រហែលពាក់កណ្តាលនៃកម្រិតនៅបង់ក្លាដែស និង ២ភាគ៣នៃកម្រិតនៅឥណ្ឌា និង ឡាវ (តារាង ១ ខ្ទង់ទី២) ។

ទោះបីជួបការលំបាកនៅអំឡុងពេលមានវិបត្តិអាស៊ីក្តី ក៏កម្ពុជា បានកាត់បន្ថយប្រេវ៉ាឡង់នៃកង្វះអាហារូបត្ថម្ភពីអត្រា ៣៨% នៅឆ្នាំ១៩៩២ មកត្រឹម ២៥% នៅឆ្នាំ២០០៦ គឺប្រហាក់ប្រហែលគ្នានឹងអត្រាភាពក្រីក្រ ។ ប៉ុន្តែមិនដូចជាភាពក្រីក្រទេ អត្រាប្រេវ៉ាឡង់នៃកង្វះអាហារូបត្ថម្ភ (ឬភាពស្រេកឃ្លានដែលគេតែងលើកឡើង) ដែលជាភាគរយនៃប្រជាជនហូបចូលកាឡូរីតិចជាងកម្រិតតម្រូវការអប្បបរមា វាស្ទើរស្មើគ្នានឹងប្រទេសបង់ក្លាដែស និងខ្ពស់ជាងប្រទេសឥណ្ឌាបន្តិចផង (តារាង ១ ខ្ទង់ទី៣) ។ ផ្ទុយទៅវិញ អត្រាប្រេវ៉ាឡង់នៃកង្វះអាហារូបត្ថម្ភនៅឡាវ ទាបជាងនៅកម្ពុជា ទោះបីឡាវមានកម្រិតភាពក្រីក្រខ្ពស់ជាង និងមានកម្រិតប្រាក់ចំណូលក្នុងមនុស្សម្នាក់ទាបជាងកម្ពុជាក្តី ។

តារាង ១៖ ការប្រៀបធៀបស្ថានភាពសន្តិសុខស្បៀង និងការអភិវឌ្ឍនៅកម្ពុជា

| | ផសស ក្នុងមនុស្សម្នាក់ (ថ្លៃដុល្លារថេរឆ្នាំ២០០០) | | អនុបាតភាពក្រីក្រត្រឹមកម្រិត ១,២៥ដុល្លារ ក្នុងមួយថ្ងៃ (% នៃប្រជាជន) | | ប្រេវ៉ាឡង់នៃកង្វះអាហារូបត្ថម្ភ (% នៃប្រជាជន) | | ប្រេវ៉ាឡង់នៃកុមារក្រិន (% នៃកុមារអាយុក្រោម ៥ឆ្នាំ) | | អត្រាមរណភាពនៃកុមារអាយុក្រោម ៥ឆ្នាំ (ក្នុង ១០០០នាក់) | |
|---|---|---|---|---|---|---|---|---|---|---|
| | 2008 | *មានស្ថានភាពប្រហែលគ្នានៅឆ្នាំ* | 2005-07 | *មានស្ថានភាពប្រហែលគ្នានៅឆ្នាំ* | 2005-07 | *មានស្ថានភាពប្រហែលគ្នានៅឆ្នាំ* | 2006-08 | *មានស្ថានភាពប្រហែលគ្នានៅឆ្នាំ* | 2008 | *មានស្ថានភាពប្រហែលគ្នានៅឆ្នាំ* |
| កម្ពុជា | 511 | | 26 | | 25 | | 40 | | 90 | |
| បង់ក្លាដែស | 462 | - | 50 | - | 26 | - | 43 | - | 54 | *2000* |
| ឡាវ | 475 | - | 44* | - | 19 | *1997* | 48 | - | 61 | *1999* |
| វៀតណាម | 647 | *2004* | 21 | *2004* | 13 | *1994* | 36 | *2002* | 14 | *<1975* |
| ឥណ្ឌា | 718 | *2003* | 42 | - | 22 | *1992* | 48 | - | 69 | *2001* |
| ចិន | 1,965 | *1993* | 16 | *2002* | 10 | *<1992* | 22* | *n.a.* | 21 | *1974* |
| ថៃ | 2,640 | *1970* | 2 | *<1981* | 17 | *1994* | 16 | *<1987* | 14 | *1973* |
| អាស៊ីខាងកើត និង ប៉ាស៊ីហ្វិក | 1,760 | *1991* | 17 | *2002* | 12 | *<1992* | 27 | *const.* | 29 | *1976* |
| សាកលលោក | 6,007 | *n.a.* | n.a. | *n.a.* | 14 | *n.a.* | 35 | *n.a.* | 67 | *1992* |

*កំណត់សម្គាល់៖ * តួលេខប៉ាន់ស្មានក្នុងឆ្នាំ២០០២, n.a. (not available) បានន័យថា គ្មានតួលេខ, cont. (constant) បានន័យថា ថេរ*

*ប្រភព៖ WDI 2010, FSS 2010, GDCGM 2010*

នៅពីរទសវត្សរ៍ចុងក្រោយនេះ កម្ពុជាក៏សម្រេចជោគជ័យគួរឱ្យកត់សម្គាល់ក្នុងការកាត់បន្ថយបញ្ហាកង្វះអាហារូបត្ថម្ភកុមារ ។ នៅឆ្នាំ១៩៩៦ មានកុមារអាយុក្រោម ៥ឆ្នាំ ប្រមាណ ៥៩% មានការលូតលាស់ក្រិន និង ៤៣% មានទម្ងន់ស្រាល ប៉ុន្តែនៅឆ្នាំ២០០៨ បញ្ហានេះបានថយចុះ ដោយអត្រាក្រិនធ្លាក់ចុះមកត្រឹម ៤០% និង អត្រាទម្ងន់ស្រាល ធ្លាក់ចុះមកត្រឹម ២៩%[២] ។ ស្របគ្នានឹងកម្រិតប្រាក់ចំណូល បញ្ហាកង្វះអាហារូបត្ថម្ភកុមារនៅកម្ពុជា មានកម្រិតខ្ពស់ជាងនៅវៀតណាម ចិន និង ថៃ ប៉ុន្តែវាទាបជាងនៅឡាវ បង់ក្លាដែស និង ឥណ្ឌា (តារាង ១ ខ្ទង់ទី៤) ។

កម្ពុជាមានអត្រាមរណភាពកុមារក្រោមអាយុ ៥ឆ្នាំ កម្រិតខ្ពស់បំផុតក្នុងចំណោមបណ្ដាប្រទេសយកមកប្រៀបធៀប (តារាង ១ ខ្ទង់ទី៥) ។ ទោះបីអត្រាមរណភាពកុមារបានថយចុះកាន់តែលឿន ជាពិសេសចាប់ពីឆ្នាំ២០០០ មកក្ដី ក៏កុមារកម្ពុជា ៩០នាក់ ក្នុងចំណោម ១០០០នាក់ បានស្លាប់ដោយសារកង្វះអាហារូបត្ថម្ភ សុខភាពទន់ខ្សោយ ឬបញ្ហាអាចបង្ការបានដទៃទៀត នៅឆ្នាំ២០០៨ ។ នៅឆ្នាំ១៩៩០ មានកុមារ ១១៧នាក់ ក្នុងចំណោម ១០០០នាក់ ត្រូវស្លាប់មុនដល់អាយុ ៥ឆ្នាំ ។ ដូច្នេះកម្ពុជា ទំនងមិនអាចសម្រេចបានទេនូវ ចំណុចទីបួននៃគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍របស់ខ្លួន ដែលសំដៅកាត់បន្ថយអត្រាមរណភាពកុមារអាយុក្រោម ៥ឆ្នាំ ឲ្យបានពីរភាគបីនៅចន្លោះឆ្នាំ១៩៩០ និង ២០១៥ ។

**កំណើនសេដ្ឋកិច្ចជាកម្លាំងជំរុញសន្តិសុខស្បៀង និងអាហារូបត្ថម្ភ**

ផ្នែកនេះធ្វើការប្រៀបធៀបការអភិវឌ្ឍរបស់កម្ពុជា ជាមួយប្រទេសផ្សេងៗ និងពិភាក្សាពីទិសដៅដែលកម្ពុជាគួរប្រកាន់យកនាពេលអនាគត ។ នៅពេល ផសស ក្នុងមនុស្សម្នាក់ និងប្រាក់ចំណូលគ្រួសារកើនឡើង ភាពក្រីក្រត្រូវធ្លាក់ចុះ ហើយសន្ទស្សន៍អភិវឌ្ឍន៍មនុស្ស ជាទូទៅតែងកើនឡើង ។ ប៉ុន្តែល្បឿននៃកំណើន និងការកែលំអអាហារូបត្ថម្ភ អាចខុសៗគ្នា ដូចមានបង្ហាញក្នុងការប្រៀបធៀបតាមប្រទេស ។ ដោយហេតុថា ដំណាក់កាលនៃការអភិវឌ្ឍត្រូវតែយកមកគិតគូរ ដើម្បីប្រៀបធៀបពីជោគជ័យរបស់ប្រទេសផ្សេងៗ ក្នុងការប្រើប្រាស់កំណើនសេដ្ឋកិច្ចជំរុញឱ្យស្ថានភាពអាហារូបត្ថម្ភល្អប្រសើរឡើង ដូច្នេះការសិក្សានេះបានភ្ជាប់សន្ទស្សន៍នៃស្ថានភាពអាហារូបត្ថម្ភ ទៅនឹង កម្រិត ផសស នៅតាមឆ្នាំផ្សេងៗ ។

ក្រាហ្វិក ២ បង្ហាញពីការផ្លាស់ប្ដូរនៃប្រេវ៉ាឡង់កង្វះអាហារូបត្ថម្ភ ធៀបនឹងកំណើនសេដ្ឋកិច្ច សម្រាប់កម្ពុជា និងបណ្ដាប្រទេសនៅអាស៊ីខាងត្បូង និងអាស៊ីអាគ្នេយ៍ ក្នុងរយៈពេលកន្លងមក ។ គេឃើញថា ជាទូទៅកង្វះអាហារូបត្ថម្ភតែងធូរស្រាលនៅពេលកម្រិតប្រាក់ចំណូលកើនឡើង ។ ការធូរស្រាលនេះមានល្បឿនលឿនជាងនៅពេលដែល ផសស ក្នុងមនុស្សម្នាក់មានកម្រិតក្រោម ៥០០ដុល្លារ ។ ស្ថានភាពនេះកើតមានពិតនៅអំឡុងពេលទាំងមូលសម្រាប់ កម្ពុជា បង់ក្លាដែស ឡាវ និងវៀតណាម ប៉ុន្តែសម្រាប់ឥណ្ឌា វាកើតមានតែនៅអំឡុងពេលដំបូងៗនៃកំណើនតែប៉ុណ្ណោះ ។ ឥណ្ឌាជាប្រទេសតែមួយគត់

២ សន្ទស្សន៍មនុស្សមាត្រវិធីចំនួនបី គេតែងប្រើប្រាស់ជាទូទៅក្នុងការកំណត់ពីបញ្ហាអាហារូបត្ថម្ភកុមារ គឺមាន កម្ពស់ធៀបនឹងអាយុ ទម្ងន់ធៀបនឹងអាយុ និងទម្ងន់ធៀបនឹងកម្ពស់ ។ គេចាត់ទុកថា កុមារមានលក្ខណៈក្រិន ទម្ងន់ស្រាល ឬស្គមស្គាំង ខ្លាំង និងធ្ងន់ធ្ងរ ប្រសិនបើពិន្ទុកម្ពស់ធៀបនឹងអាយុ ពិន្ទុទម្ងន់ធៀបនឹងអាយុ ឬពិន្ទុទម្ងន់ធៀបនឹងកម្ពស់ របស់ពួកគេស្ថិតក្រោមកម្រិតគ្រោះថ្នាក់មួយចំនួន ។ សន្ទស្សន៍ទាំងបីនេះ មានអត្ថន័យផ្សេងៗគ្នាស្ដីពីអាហារូបត្ថម្ភកុមារ និងមិនអាចប្រើប្រាស់ប្ដូរផ្លាស់គ្នាបានទេ (WHO 1995) ។ តទៅនេះ អត្ថបទនឹងផ្ដោតទៅលើភាពក្រិន ពីព្រោះសន្ទស្សន៍នៃកម្ពស់ធៀបនឹងអាយុ មានលក្ខណៈសមស្របបំផុតសម្រាប់កំណត់ពីកង្វះអាហារូបត្ថម្ភរយៈពេលវែង និងបកស្រាយពីអន្តរកម្មរវាងសុខភាព និងអាហារូបត្ថម្ភ ។

ក្រាហ្វិក ២៖ ទំនាក់ទំនងរវាងអត្រាប្រេវ៉ាឡង់កង្វះអាហារូបត្ថម្ភ និង ផសស ក្នុងមនុស្សម្នាក់




*កំណត់សម្គាល់៖ ទិន្នន័យពីឆ្នាំ១៩៩២ ១៩៩៧ ២០០២ និង ២០០៧*

*ប្រភព: WDI 2010, FSS 2010.*

ដែលមានអត្រាប្រេវ៉ាឡង់កង្វះអាហារូបត្ថម្ភកើនឡើង នៅពេលប្រាក់ចំណូលកើនកាន់តែលឿនក្នុងប៉ុន្មានឆ្នាំថ្មីៗ ។ ទោះបីកម្ពុជា បានកាត់បន្ថយគួរឱ្យកត់សម្គាល់នូវអត្រាស្រេកឃ្លានក្នុងអំឡុងពេលដំបូងៗនៃកំណើនក្តី ក៏ការកាត់បន្ថយនេះបានចាប់ផ្តើមថយល្បឿននាពេលថ្មីៗ[៣] ។

នៅ ចិន និងវៀតណាម ទំនាក់ទំនងរវាងកង្វះអាហារូបត្ថម្ភ និងកម្រិតប្រាក់ចំណូល មានលក្ខណៈស្រដៀងគ្នាណាស់ ដោយសារខ្សែកោងដែលតំណាងឱ្យប្រទេសទាំងពីរមាននិន្នាការដូចគ្នា ។ ដូច្នេះ ទំនាក់ទំនងរវាងការកាត់បន្ថយភាពស្រេកឃ្លាន និងកំណើនប្រាក់ចំណូល នៅវៀតណាម ទំនងអាចទាយទុកបានផ្អែកតាមដំណើរការពីមុននៅចិន ។ ថៃមានកម្រិតប្រាក់ចំណូលក្នុងមនុស្សម្នាក់ ខ្ពស់ជាងប្រទេសជ្រើសរើសឯទៀតៗ នៅចំណុចចាប់ផ្តើមនៃខ្សែកោងរបស់ខ្លួន ប៉ុន្តែមានអត្រាប្រេវ៉ាឡង់កង្វះអាហារូបត្ថម្ភ ខ្ពស់ជាងចិន នៅពេលចិនសម្រេចបាន កម្រិតប្រាក់ចំណូលក្នុងមនុស្សម្នាក់ប្រហាក់ប្រហែលគ្នានៅខាងចុងខ្សែកោង ។ ទោះបីល្បឿនកាត់បន្ថយភាពស្រេកឃ្លាននៅថៃ វាលឿនជាងនៅចិន បើធៀបនឹងល្បឿនកំណើនប្រាក់ចំណូល ប៉ុន្តែនៅត្រង់កម្រិតប្រាក់ចំណូលខ្ពស់ ថៃមានអត្រាប្រេវ៉ាឡង់កង្វះអាហារូបត្ថម្ភ ខ្ពស់ជាងចិនគួរឱ្យកត់សម្គាល់ ។

ក្រាហ្វិក ៣ បង្ហាញពីអត្រាប្រេវ៉ាឡង់កង្វះអាហារូបត្ថម្ភកុមារ ធៀបនឹងកម្រិតប្រាក់ចំណូលក្នុងមនុស្សម្នាក់នៅកម្ពុជា និងប្រទេសបួនទៀតក្នុងពេលកន្លងមក ។ ខ្សែកោងចាប់ផ្តើមពីកម្រិតខុសៗគ្នានៃប្រាក់ចំណូលក្នុងមនុស្សម្នាក់ និងអត្រាប្រេវ៉ាឡង់កង្វះអាហារូបត្ថម្ភ ប៉ុន្តែស្ទើរគ្រប់ប្រទេស បានកាត់បន្ថយកង្វះអាហារូបត្ថម្ភកុមារ នៅពេលកម្រិតប្រាក់ចំណូលកើនឡើង លើកលែងតែប្រទេសឡាវ ដែលកម្រិតកង្វះអាហារូបត្ថម្ភកុមារស្ទើរតែគ្មានប្រែប្រួលអ្វីសោះ នៅពេលដែលប្រាក់ចំណូលក្នុងមនុស្សម្នាក់កើនឡើងពី ៣០០ដុល្លារ ដល់ជាង ៤០០ដុល្លារ ។ ការប្រៀបធៀបនេះបង្ហាញថា នៅត្រឹមកម្រិតប្រាក់ចំណូលប្រហាក់ប្រហែលគ្នា អត្រាប្រេវ៉ាឡង់កង្វះអាហារូបត្ថម្ភកុមារ វាខុសគ្នាច្រើនរវាងប្រទេសទាំងប្រាំ ។ ដោយឡែកនៅត្រង់កម្រិតប្រាក់ចំណូលក្នុងមនុស្សម្នាក់ ទាបជាង ៣០០ដុល្លារ កម្ពុជាមានអត្រាប្រេវ៉ាឡង់កង្វះអាហារបត្ថម្ភកុមារខ្ពស់បំផុត គឺខ្ពស់ជាង បង់ក្លាដែស និងវៀតណាម នៅត្រង់កម្រិតប្រាក់ចំណូលប្រហាក់ប្រហែលគ្នាទៀតផង ។ នៅពេលប្រាក់ចំណូលក្នុងមនុស្សម្នាក់ កើនពី ៣០០ ដល់ ៤០០ដុល្លារ អត្រាប្រេវ៉ាឡង់កង្វះអាហារូបត្ថម្ភកុមាររបស់វៀតណាម បានធ្លាក់ចុះគួរឱ្យកត់សម្គាល់ ប៉ុន្តែនៅអំឡុងពេលនោះ ខ្សែកោងរបស់កម្ពុជាមានលក្ខណៈរាបជាងខ្សែកោងរបស់វៀតណាម គឺបានន័យថា សម្រាប់កំណើនប្រាក់ចំណូលក្នុងមនុស្សម្នាក់ប្រហាក់ប្រហែលគ្នាពី ៣០០ ដល់ ៤០០ដុល្លារនេះ ការកាត់បន្ថយអត្រាប្រេវ៉ាឡង់កង្វះអាហារូបត្ថម្ភកុមារ នៅកម្ពុជា វាមានតិចជាងនៅវៀតណាម ។

នៅឯប្រទេសបង់ក្លាដែស នៅពេលប្រាក់ចំណូលក្នុងមនុស្សម្នាក់មានកម្រិតទាប អត្រាប្រេវ៉ាឡង់កង្វះអាហារូបត្ថម្ភកុមារ មានកម្រិតខ្ពស់បំផុត ។ ប៉ុន្តែនៅពេលវាកើនឡើងបន្តិចពោលគឺ ប្រាក់ចំណូលក្នុងមនុស្សម្នាក់កើនពី ២៥០ ដល់ ៤០០ដុល្លារ អត្រានេះបានធ្លាក់ចុះគួរឱ្យកត់សម្គាល់ ។ បង់ក្លាដែស អាចកាត់បន្ថយកង្វះអាហារូបត្ថម្ភកុមារបានជោគជ័យបែបនេះ ដោយសារមានការវិនិយោគធំៗទៅលើកម្មវិធីផ្តោតចំគោលដៅជាច្រើន ។ នៅឯប្រទេសឥណ្ឌា នៅកម្រិតប្រាក់ចំណូលក្នុងមនុស្សម្នាក់ក្បែរ ៥០០ដុល្លារ ស្ថានភាពអាហារូបត្ថម្ភរបស់

ក្រាហ្វិក ៣៖ ទំនាក់ទំនងរវាងអត្រាប្រេវ៉ាឡង់កង្វះអាហារូបត្ថម្ភកុមារ និង ផសស ក្នុងមនុស្សម្នាក់




*កំណត់សម្គាល់៖ ទិន្នន័យទទួលបានពីរវាងឆ្នាំ១៩៨៧ និង ២០០៨ ។*

*ប្រភព៖ WDI 2010, GDCGM 2010.*

៣ ចំណុចស្រួចៗនៅលើខ្សែកោងសម្រាប់កម្ពុជា និងបង់ក្លាដែស បង្ហាញពីផលប៉ះពាល់នៃវិបត្តិអាស៊ីនៅឆ្នាំ១៩៩៧ ។

ក្រាហ្វិក ៤៖ ទំនាក់ទំនងរវាងអត្រាមរណាភាពកុមារ និង ផសស ក្នុងមនុស្សម្នាក់




*កំណត់សម្គាល់៖ ទិន្នន័យបានពីឆ្នាំដូចគ្នា នៅរវាងឆ្នាំ១៩៦០ និង ២០០៨ ។*

*ប្រភព: WDI 2010, GDCGM 2010.*

កុមារតូចៗមានលក្ខណៈអាក្រក់បំផុត ។ ហើយនៅពេលប្រាក់ចំណូលក្នុងមនុស្សម្នាក់ កើនដល់ ៦០០ដុល្លារ (នៅចុងខ្សែកោង) អត្រាប្រេវ៉ាឡង់កង្វះអាហារូបត្ថម្ភកុមារនៅតណ្ឌ ថយចុះតែតិចតួចប៉ុណ្ណោះ ។

ក្រាហ្វិក ៤ បង្ហាញពីអត្រាមរណភាពរបស់កុមារ ធៀបនឹង ផសស ក្នុងមនុស្សម្នាក់ ក្នុងពេលកន្លងមក ។ ប្រហែលគ្នានឹងលទ្ធផលដូចមានបង្ហាញក្នុងក្រាហ្វិក ១ ដែរ អត្រាមរណភាពរបស់កុមារ ធ្លាក់ចុះយ៉ាងខ្លាំង នៅពេលប្រាក់ចំណូលក្នុងមនុស្សម្នាក់កើនឡើង តែនៅទាបជាងកម្រិត ៥០០ដុល្លារ ។ បន្ទាប់ពីអត្រាមរណភាពរបស់កុមារ ធ្លាក់មកត្រឹម ៥០នាក់ក្នុង ១០០០នាក់ និងប្រាក់ចំណូលក្នុងមនុស្សម្នាក់កើនខ្ពស់ជាង ៥០០ដុល្លារ ការកាត់បន្ថយអត្រាមរណភាពកុមារ ក៏ថយល្បឿន ។ ប៉ុន្តែវៀតណាមមានការវិវត្តខុសប្លែកពីគេ ដោយអត្រាមរណភាពកុមារបន្តធ្លាក់ចុះយ៉ាងខ្លាំងតទៅទៀត ក្រោយពេលសម្រេចបានអត្រាមរណភាពកុមារ ត្រឹម ៥០នាក់ក្នុង ១០០០នាក់ និង កម្រិតប្រាក់ចំណូលក្នុងមនុស្សម្នាក់លើសពី ៥០០ដុល្លារ ។ នៅកម្រិតប្រាក់ចំណូលទាបជាង ៥០០ដុល្លារ ខ្សែកោងកម្ពុជា មានលក្ខណៈរាបស្មើបំផុត ក្នុងចំណោមប្រទេសជ្រើសរើសទាំងអស់ ។ ស្ថានភាពនេះបង្ហាញថា ការកែលំអសុខុមាលភាពរបស់ក្រុមកុមារទន់ខ្សោយបំផុតនៅកម្ពុជា មានល្បឿនយឺត ។

## សេចក្តីសន្និដ្ឋាន

ទោះបីមានកំណើនសេដ្ឋកិច្ចខ្ពស់ និងការរីកចម្រើនគួរឱ្យកត់សម្គាល់ក្នុងការកាត់បន្ថយភាពក្រីក្រ ភាពស្រេកឃ្លាន និងអាហារូបត្ថម្ភនៅប៉ុន្មានឆ្នាំថ្មីៗនេះក្តី ក៏កម្ពុជានៅតែស្ថិតក្នុងចំណោមប្រទេសក្រីក្របំផុតនៅអាស៊ីខាងត្បូង និងអាស៊ីអាគ្នេយ៍ ដោយមានអត្រាប្រេវ៉ាឡង់កង្វះអាហារូបត្ថម្ភកុមារកម្រិតខ្ពស់បំផុត ។ ការប្រៀបធៀបតាមប្រទេសក្នុងឯកសារនេះបង្ហាញថា ស្ថានភាពការអភិវឌ្ឍ និងសន្តិសុខស្បៀងនៅកម្ពុជា មានលក្ខណៈស្រដៀងគ្នានឹងនៅឡាវ និងបង់ក្លាដែសនាពេលបច្ចុប្បន្ន និងនៅវៀតណាមនាដើមទសវត្សរ៍ ២០០០ និង ថៃនាចុងទសវត្សរ៍ ១៩៧០ ។ និន្នាការនេះបង្ហាញថា ជាទូទៅកម្ពុជាដើរតាមលំនាំរបស់វៀតណាម និងចិន ដែលនៅទីនោះ កំណើនសេដ្ឋកិច្ចខ្ពស់បានហូរជ្រាបដល់ប្រជាជនស្រទាប់ក្រោម ហើយភាពស្រេកឃ្លាន និងកង្វះអាហារូបត្ថម្ភកុមារ បានថយចុះគួរឱ្យកត់សម្គាល់ គឺផ្ទុយពីការអភិវឌ្ឍនៅតណ្ឌ ដែលបានហូររំលងប្រជាជនអ្នកជួបកង្វះអាហារូបត្ថម្ភ ។ ប៉ុន្តែក្នុងប៉ុន្មានឆ្នាំថ្មីៗ កម្ពុជាបានងាកចេញពីមាគ៌ាមានជោគជ័យរបស់វៀតណាម និងចិន ដែលក្នុងនោះកំណើននិងស្ថានភាពអាហារូបត្ថម្ភល្អប្រសើរវាកើតឡើងព្រមគ្នា។ ម្យ៉ាងទៀត វិសមភាពនៃប្រាក់ចំណូលបានកើនឡើងស្របគ្នានឹងកំណើនសេដ្ឋកិច្ច ហើយអត្រាកំណើនប្រជាជន ក៏នៅតែមានកម្រិតខ្ពស់ ។ កត្តាទាំងនេះរារាំងកម្ពុជាក្នុងការកែលំអសន្តិសុខស្បៀង និងស្ថានភាពអាហារូបត្ថម្ភ ជាពិសេសនៅពេលកំណើនសេដ្ឋកិច្ចបានថយចុះ ដោយសារឥទ្ធិពលនៃការធ្លាក់ចុះសេដ្ឋកិច្ចសាកលនាពេលថ្មីៗ ។

ការពិភាក្សាខាងលើនេះបង្ហាញថា ត្រូវមានកិច្ចប្រឹងប្រែងថែមទៀត ដើម្បីរុញច្រានកម្ពុជា ឱ្យដើរចំមាគ៌ាប្រកបដោយប្រសិទ្ធភាពរបស់វៀតណាម និងចិន និងប្រើប្រាស់កំណើនឲ្យបានកាន់តែសក្តិសិទ្ធិក្នុងការកែលំអស្ថានភាពអាហារូបត្ថម្ភ និងសន្តិសុខស្បៀងសម្រាប់គ្រប់ៗគ្នានាពេលអនាគត ។ បង់ក្លាដែសមានកំណើនតិចជាងកម្ពុជាក៏ពិតមែន ប៉ុន្តែបទពិសោធន៍របស់បង់ក្លាដែសអាចផ្តល់ជាគំរូដ៏មានប្រយោជន៍សម្រាប់កម្ពុជា ពីព្រោះសកម្មភាពផ្តោតចំគោលដៅជាច្រើននៅប្រទេសនោះ បានជំរុញឱ្យស្ថានភាពអាហារូបត្ថម្ភកុមារប្រែប្រួលប្រសើរឡើងជាខ្លាំង ។

## ឯកសារយោង

FAO (Food and Agriculture Organisation of the United Nations) (1996), World Food Summit: Rome Declaration on World Food Security, http://www.fao.org/docrep/003/w3613e/w3613e00 (last accessed October 2010)

FAO (2009), Declaration of the World Summit on Food Security in Rome, http://www.fao.org/fileadmin/templates/wsfs/Summit/Docs/Final_Declaration/WSFS09_Declaration.pdf (last accessed 11 October 2010)

FSS (Food Security Statistics) (2010), Database of the Food and Agriculture Organisation of the United Nations, http://www.fao.org/economic/ess/food-security-statistics/en/ (last accessed October 2010)

GDCGM (Global Database of Child Growth and Malnutrition) (2010), Database of the World Health Organisation, http://www.who.int/nutgrowthdb/en/ (accessed October 2010)

Naron, H. C. (2009), *Cambodian Economy: Charting the Course of a Bright Future — A Survey of Progress*, Problems, and Prospects (Phnom Penh)

WDI (World Development Indicators) (2010), Database of the World Bank, http://data.worldbank.org/ (last accessed 11 October 2010)

WHO (World Health Organisation) (1995), Physical Status: The use and Interpretation of Anthropometry, report of a WHO expert committee, WHO Technical Report 854 (Geneva: WHO)